# ជំងឺសំខាន់ៗរបស់ជ្រូក

រៀបចំដោយ

**បណ្ឌិត ជីវ ភីនី**

Chiv_phiny@yahoo.com / chphiny@celagrid.org

មជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និង កសិកម្ម (សែលអាគ្រីត)



## ការបែងចែកប្រភេទឱសថ និងការប្រើប្រាស់

ឱសថជាសារធាតុសកម្ម ហើយមានសកម្មភាពផ្សេងៗគ្នា

ដោយយោងទៅតាមប្រភេទសកម្មភាព

គេបែងចែកឱសថជា ៧ ប្រភេទ

## ការបែងចែកប្រភេទឱសថ:

១- វីតាមីន និងសារធាតុរ៉ែ ត្រូវការចាំបាច់សម្រាប់ទ្រទ្រង់សុខភាព ធ្វើឱ្យមានការលូតលាស់ និងធ្វើឱ្យការបន្តពូជប្រព្រឹត្តិទៅល្អធម្មតា។

២- អង់ទីប៊ីយ៉ូទិច ជាប្រភេទប្រឆាំងពពួកបាក់តេរី

៣- ឱសថប្រឆាំងពួកបរ៉ាសិត គឺមានសកម្មភាពប្រឆាំងបរ៉ាសិតខាងក្នុង និងខាងក្រៅ

៤- ឱសថប្រឆាំងនឹងការរលាក គឺអាចទប់ទល់នឹងការរលាក គ្រុនក្តៅ និងឈឺចាប់

៥- អ័រម៉ូន មានសកម្មភាពជួយរំញោចប្រដាប់បន្តពូជ

៦- វ៉ាក់សាំង ការពារជម្ងឺ ជាពិសេសជម្ងឺបង្កឡើងដោយវីរុស

៧- ថ្នាំបាញ់សម្លាប់មេរោគ ជួយកំចាត់ពួកបាក់តេរី វីរុស ផ្សិត ដែលមាននៅក្នុងបរិយាកាស



## អ្វីទៅជាមេរោគ?

- មេរោគជាសត្វល្អិតដែលមានជីវិតដែលអាចបង្កជាជំងឺដល់សត្វ និងមនុស្ស។
- មេរោគបង្កជំងឺមាន:
- វីរុស: ជាសត្វល្អិតតូចៗដែលមិនអាចមើលឃើញដោយភ្នែកទទេ ហើយ ពពួកថ្នាំ អង់ទីប៊ីយ៉ូទិច មិនអាចសំលាប់ ឬ បង្អាក់សកម្មភាពរបស់វាបានឡើយ ។ ជំងឺ ប៉េស្ត៍ អុតក្តាម
- បាក់តេរី: ជាសត្វល្អិតដែលបង្កជាជំងឺ ប៉ុន្តែពពួកថ្នាំ អង់ទីប៊ីយ៉ូទិច អាចសំលាប់ ឬ បង្អាក់សកម្មភាពរបស់វាបាន ។ ជំងឺសារទឹកជ្រូក កព្រា
- បរាសិត: ជាសត្វល្អិតរស់លើខ្លួនសត្វ និងបំផ្លាញសត្វ។ព្រូនមូល ព្រូនសំប៉ែត ចៃ អង្កា រុយ ដង្កែ......។

# គោលការណ៍នៃការព្យាបាល

- ព្យាបាលទៅតាមរោគសញ្ញា: គឺត្រូវប្រើថ្នាំទៅតាមរោគសញ្ញា ឧទាហរណ៍: សត្វឡើងកំដៅ យើងត្រូវប្រើថ្នាំបញ្ចុះកំដៅ ដូចជា ប៉ារាសេតាម៉ុល អាណាហ្សាំង....។ សត្វរាគត្រូវប្រើថ្នាំបំបាត់រាគ ដូចជា ទីឡូស៊ីន បាក់ទ្រីម ហ្គាណាដង់ អូរីអូ.....។
- ព្យាបាលទៅតាមមូលហេតុ: យេងត្រូវស្វែងរកមូលហេតុដែលបង្កអោយមានជំងឺ ។ ឧទាហរណ៍: កូនជ្រូករាគដោយសារចំណី យើងត្រូវកែសំរួលចំណី ។ ប្រសិនបើជ្រូកឈឺ ដោយសារជំងឺសារទឹក យើងត្រូវប្រើថ្នាំ អង់ទីប៊ីយ៉ូទិច ។

# ជំងឺប៉េស្តជ្រូក

## ➢ សភាពបង្កជំងឺ :

✓ វាអាស្រ័យទៅលើដំណើរការបំបែកខ្លួនរបស់វីរុសក្នុងពេលដែលវាចូលទៅក្នុងជ្រូក។

✓ វាអាចបង្កជំងឺលឿនប្រសិនបើវីរុសមានការបំបែកខ្លួនលឿន ឬមធ្យម ឬបង្កជំងឺយឺត ប្រសិនបើវីរុសបំបែកខ្លួនយឺត មានន័យថាជំងឺអាច :

- ស្រួចស្រាវ គឺធ្វើឱ្យជ្រូកងាប់យ៉ាងឆាប់រហ័ស និង
- មិនស្រួចស្រាវ ដែលជាញឹកញយជ្រូកមិនងាប់ទេ តែជ្រូកខ្សោយនិងក្រិន (លូតលាស់យឺត)។

# ជំងឺប៉េស្តជ្រូក

- ការចំលងជំងឺ :
  - ✓ អាចចំលងតាមរយៈជ្រូកឈឺ
  - ✓ តាមទឹកកាមនៅពេលបង្កាត់
  - ✓ តាមទងសុកការចំលងនេះកើតមានលើកូនក្នុងពោះ
  - ✓ តាមចំណីដែលចំអិនមិនបានល្អ ដូចជាសំណល់ផ្ទះបាយដែលមានសំណល់សាច់ជ្រូកដែលមេរោគ។
  - ✓ តាមសំភារៈផ្សេងៗទៀត កសិករ ភ្នាក់ងារសុខភាពសត្វភូមិ ដែលទៅមើលកសិដ្ឋានចិញ្ចឹមជ្រូក ដែលមានជំងឺហើយពួកគេ ពាំនាំវីរុសតាមស្បែកជើង និងសំលៀកបំពាក់...។

8

# ជំងឺប៉េស្តជ្រូក

- រោគសញ្ញា :
  - ✓ រោគសញ្ញា ជាទូទៅកើតមានពី ៥-១០ ថ្ងៃ បន្ទាប់ពីមេរោគជ្រាបចូល។
  - ✓ រោគសញ្ញាដែលច្រើនតែកើតមានគឺ សីតុណ្ហភាពដងខ្លួនឡើងខ្ពស់ គឺពី ៤០,៥-៤១,៥ អង្សាសេ ហើយអង់ទីប៊ីយ៉ូទិចមិនអាចបញ្ចុះកំដៅបានទេ។
  - ✓ ជ្រូកអាចបញ្ចេញវីរុសមកក្រៅមុនពេល និងក្រោយពេលបង្ហាញរោគសញ្ញា ហើយសត្វអាចសាយភាយ ជំងឺបាន

9

# ជំងឺប៉េស្តជ្រូក

## ➢ ជំងឺស្រួចស្រាវ :

- ✓ ជាញឹកញយច្រើនកើតមាននៅលើជ្រូក ទំងន់ពី ៣០-៦០ គ.ក្រ
- ✓ គ្រុនក្តៅលើស ៤០,៥ អង្សាសេ
- ✓ ខ្សោយ និងស្ពឹកស្រពន់
- ✓ រលាកកែវភ្នែក
- ✓ ដើរពាន់ជើង
- ✓ ស្បែកមានពណ៌ស្វាយ
- ✓ ជំងឺផ្សេងខ្លះទៀតក៏កើតមានឡើងដែរ ដូចជា សាល់ម៉ូណេឡា និង រោគសញ្ញាផ្លូវដង្ហើម
- ✓ អត្រាស្លាប់កំឡុងពេលមួយសប្តាហ៍ខ្ពស់បន្ទាប់ពីលេចរោគសញ្ញា។



# ជំងឺប៉េស្តជ្រូក

## ➢ ជំងឺមិនស្រួចស្រាវ :

- ✓ កើតមានឡើងនៅពេលដែលមេរោគមានសកម្មភាពមិនខ្លាំងក្លា។
- ✓ កើតមានឡើងនៅពេលជ្រូកធ្វើវ៉ាក់សាំងតែមានគុណភាពអន់ដូចជាការថែរក្សាវ៉ាក់សាំងមិនបានល្អ ឬ ការធ្វើកម្មវិធីវ៉ាក់សាំង មិនបានគ្រប់គ្រាន់។
- ✓ មានគ្រុនក្តៅនៅថ្ងៃទី ១
- ✓ រលាកស្បែក និង រោមបះ
- ✓ ត្រចៀកពណ៌ស្វាយ

# ជំងឺប៉េស្តជ្រូក

## ➢ ករណីលើមេជ្រូក :

- ✓ កូនជ្រូកកើតមកងាប់
- ✓ កូនងាប់ស្វិត
- ✓ រលូត
- ✓ កូនជ្រូកទើបកើតមកខ្សោយ និងមានទំហំតូច។



# ជំងឺប៉េស្តជ្រូក

➢ រោគសញ្ញាមួយដែលច្រើនកើតមានជាទូទៅគឺ :

- ✓ កូនជ្រូកទើបកើតមានសភាពញ័រ
- ✓ វាបង្ហាញច្បាស់ថាមាន ប្រភេទវីរុសដែលមានសកម្ម ខ្សោយកើត មាននៅក្នុងកសិដ្ឋាន ឬ
- ✓ ដោយសារការធ្វើវ៉ាក់សាំង មិនបាន គ្រប់គ្រាន់។